# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលជលផល**
**នាយកដ្ឋានអភិរក្សជលផល**

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធានកម្មវិធី UN-REDD+ កម្ពុជា**

**<u>កម្មវត្ថុ</u>** : របាយការណ៍ស្តីពី ការផ្សព្វផ្សាយផ្ទាំងរូបភាពពីអត្ថប្រយោជន៍នៃព្រៃកោងកាង ដល់អ្នកដែលរស់នៅស្រុកព្រៃនប់ ស្ថិតនៅមាត់ទឹក តែងតែប្រកបរបរចិញ្ចឹមជីវិតនៅកន្លែងអភិរក្ស របស់កម្មវិធី REDD+ កម្ពុជា

**<u>យោង</u>**:
- លិខិតបេសកកម្មលេខ ៦២៣ ជ.ផ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៤ របស់រដ្ឋបាលជលផល ។
- ផែនការកម្មវិធី UN-REDD ថវិកាឆ្នាំ២០១៤ Outcome 2:Development of National Redd+ Strategy and Implementation Framework Activities 2.4 Investigation on how the Redd+ Framework can support management of flooded forests and Mangrove Areas Managed by Fisheries Administration Under Strategic Planning Framework on Fisheries.
- គម្រោងអភិរក្សនិងដាំដុះព្រៃលិចទឹក និងព្រៃកោងកាងឡើងវិញដើម្បីជួយបង្កើនកាបូនស្តុកនិងបន្ថយការបំភាយកាបូន

ន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ក្រុមការងារយើងខ្ញុំសូមរាយការណ៍ជូនឯកឧត្តមមេត្តាជ្រាបដូចខាងក្រោម៖

### ១-គោលបំណង

គោលបំណងនៃបេសកកម្មនេះដើម្បីផ្សព្វផ្សាយផ្ទាំងរូបភាពស្តីពីអត្ថប្រយោជន៍នៃកោងកាង ដល់អាជ្ញាធរនាយខណ្ឌរដ្ឋបាលជលផល និងសហគមន៍ ព្រមទាំងប្រជាពលរដ្ឋស្រុកព្រៃនប់ដើម្បីៈ

- ឲ្យប្រជាពលរដ្ឋបានយល់អំពីសាវតា និងដំណើរការ នៃការអនុវត្តនៃកម្មវិធី REDD+ កម្ពុជា
- យល់អំពីអត្ថប្រយោជន៍នៃ ការអភិរក្សព្រៃលិចទឹកចំពោះវិស័យជលផល និងមនុស្ស
- ចេះថែរក្សា ការពារ និងអភិរក្សព្រៃកោងកាងប្រកបដោយនិរន្តភាព

### ២-សមាសភាពចូលរួម

សមាសភាពចូលរួមចំនួន ១២៦ នាក់ ក្នុងនោះស្រីចំនួន ៥៨ នាក់ មកពីៈ

- ក្រុមការងារសម្របសម្រួលរបស់កម្មវិធី REDD+ កម្ពុជា នៃនាយកដ្ឋានអភិរក្សជលផលចំនួន ០២ រូប

| | |
|---|---|
| - នាយខណ្ឌរដ្ឋបាលជលផលខេត្តព្រះសីហនុ | ០១ រូប |
| - នាយផ្នែកសង្កាត់រដ្ឋបាលជលផល | ០៥ រូប |
| - មេឃុំ | ០១ រូប |
| - ប្រជាពលរដ្ឋភូមិទួលទទឹង | ២០ រូប |
| - ប្រជាពលរដ្ឋភូមិជំពូខ្មៅ | ៥១ រូប |
| - ប្រជាពលរដ្ឋភូមិបែកក្រង់ | ៤៦ រូប |
| **សរុប** | **១២៦ រូប** |

### ៣-សកម្មភាពការងារ

ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ ក្រុមការងាររបស់នាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផលបានធ្វើការផ្សព្វផ្សាយផ្ទាំងរូបភាពពីអត្ថប្រយោជន៍នៃព្រៃលិចទឹកដល់អាជ្ញាធរឃុំផ្លូវទូកដូចជាៈ ទីប្រឹក្សាឃុំ នាយរងខណ្ឌ នាយផ្នែក នៃរដ្ឋបាលជលផល ក្រុមល្បាត សហគមន៍នេសាទ និង ប្រជាពលរដ្ឋស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ជាកិច្ចចាប់ផ្តើមមន្ត្រីសម្របសម្រួលនៃនាយកដ្ឋានអភិរក្ស បានចែកផ្ទាំងរូបភាពដល់អ្នកចូលរួមពិនិត្យមើលថាតើពួកគាត់យល់ឃើញយ៉ាងណាដែរ? ពួកគាត់បានយកទៅអានហើយយល់ឃើញថា ផ្ទាំងរូបភាពនេះចែកចេញជាពីរ មួយផ្នែកអាក្រក់ និងមួយផ្នែកទៀតល្អ។ ប៉ុន្តែពួកគាត់ពុំបានយល់ឲ្យបានស៊ីជម្រៅជាងនេះទេ។

ជាបន្តក្រុមអ្នកសម្របសម្រួលបានពន្យល់ដល់ប្រជាពលរដ្ឋ អំពីអត្ថន័យនៃផ្ទាំងរូបភាពព្រៃលិចទឹកសាប និងប្រៃថ: ព្រៃលិចទឹកសាបគឺជាព្រៃដែលរស់នៅតំបន់ទំនាបលិចទឹក ពិសេសតំបន់ទន្លេសាប ឯព្រៃលិចទឹកប្រៃឬភ្លៀវគឺជាព្រៃកោងកាង។ ក្នុងនោះកម្មវិធីរេដបូកបានជ្រើសរើសយកខេត្តចំនួនពីរគឺ: ព្រៃទឹកសាបមានទីតាំងនៅក្នុងឃុំផ្លូវទូក (អតីតឡូត៍លេខ១) ស្រុក កំពង់លែង ខេត្តកំពង់ឆ្នាំង និងព្រៃកោងកាងស្ថិតក្នុងខេត្តព្រះសីហនុ។ ប្រភេទទីតាំងព្រៃទាំងពីរនេះត្រូវបានអភិរក្សក្រោមការឧបត្ថម្ភរបស់កម្មវិធីREDD+កម្ពុជា។

ផ្នែកខាងឆ្វេងនៃរូបភាពបានបង្ហាញថា ពេលកាប់ឬដុតព្រៃឈើ ផ្សែងរោងចក្រ ផ្សែងកាណូតបានបំភាយចេញនូវឧស្ម័នកាបូនិក បង្កឲ្យមានខ្យល់ពុល នឹងបង្កើតជាឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងធ្វើឲ្យបរិយាកាសប្រែប្រួល បាត់បង់អុកស៊ីសែន ជាពិសេសធ្វើឲ្យបាត់បង់នូវ ប្រភពចំណី ជម្រក កន្លែងពងកូនរបស់មច្ឆជាតិ ដោយសារការ បាត់បង់ព្រៃឈើ។ ដូចនេះព្រៃឈើវាផ្តល់ផលប្រយោជន៍ដល់អស់លោកអ្នកតាំងពីកើតដល់ស្លាប់។

**៤-ផលវិបាក**

១- ប្រជាពលរដ្ឋ ៧០% ពុំចេះអក្សរដែលពិបាកធ្វើការពន្យល់ដល់ពួកគាត់

២- ចម្ងាយពីភូមិមួយទៅភូមិមួយទៀតដាច់ឆ្ងាយពីគ្នា ពិបាកនិងអញ្ជើញពួកគាត់មកចូលរួម

៣- ភាគច្រើនបុរសជាមេគ្រួសារមានការរវល់ជាប់ការងារនេសាទ ឬធ្វើស្រែចំការ ច្រើនតែឲ្យប្រពន្ធឬនារីមកចូលរួម

**៥-ដំណោះស្រាយ**

សហគមន៍នេសាទ អាជ្ញាធរឃុំ នាយរងខណ្ឌរដ្ឋបាលជលផលព្រះសីហនុ និងនាយសង្កាត់រដ្ឋបាលជលផលព្រៃនប់បានសំណូមពរថាគួរមានការផ្សព្វផ្សាយ ដោយមិនកំនត់បរិមាណដល់ប្រជាពលរដ្ឋចូលរួមទូទៅក្នុងពេលជិតប្រារព្ធពិធីបុណ្យទាននៅក្នុងតំបន់ដើម្បីឲ្យពួកគាត់បានយល់និងស្គាល់តំបន់អភិរក្សទើបគាត់ចូលរួមការពារ និងឈប់កាប់រានព្រៃធ្វើចំការបន្តទៀត។

**៦-លទ្ធផលការងារ**

ការផ្សព្វផ្សាយនេះប្រជាពលរដ្ឋបានយល់ដឹងកាន់តែច្បាស់ថែមទៀត នូវផលប្រយោជន៍ព្រៃលិចទឹក មិនគ្រាន់តែប្រភពចំណី ជម្រក កន្លែងពងកូនរបស់មច្ឆជាតិប៉ុណ្ណោះទេ វាជួយបន្សុទ្ធខ្យល់បរិយាកាស ទប់ទល់នូវបំរែបំរួលបរិយាកាស ។ កិច្ចផ្សព្វផ្សាយនេះប្រជាពលរដ្ឋបានចូលរួមគ្រប់ផែនការដែលបានគ្រោងទុកប្រកបដោយភាពស្និទ្ធស្នាល ជាទីបំផុត។

**៧-ទិសដៅបន្ត**

ក្រុមការងារនាយកដ្ឋានអភិរក្សជលផលនៃរដ្ឋបាលជលផលនឹងចុះទៅធ្វើការផ្សព្វផ្សាយបន្ថែម ទៀតស្តីពីតំបន់ការពារព្រៃលិចទឹកដល់សហគមន៍មូលដ្ឋាន ដើម្បីឲ្យគាត់ស្គាល់តំបន់អភិរក្ស និងចូលរួមជួយការពារព្រៃលិចទឹកឈប់កាប់រានបន្តទៀត។

**៨-អនុសាសន៍**

ការផ្សព្វផ្សាយ មិនត្រូវមានការកំនត់ គួរណាស់តែគូជាផ្ទាំងរូបភាព បោះដាក់តាំង ផ្សាយនៅទីប្រជុំជនតំបន់ព្រៃលិចទឹក ឬផលិតជាខ្សែវីដេអូ ងាយៗ ដោយបង្កប់នៃការពារ ថែរក្សា និងអភិរក្សផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានកម្មវិធីរេដ មេត្តាជ្រាបជារបាយការណ៍ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤

អ្នកធ្វើរបាយការណ៍

លី សុធា

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានអភិរក្សជលផល

ប៊ុន រាសី

Date: 27/03/2014

# រូបភាពសកម្មភាព
# ផ្សព្វផ្សាយផ្ទាំងរូបភាពព្រៃលិចទឹក នៃកម្មវិធីរេដបូក



រូបភាពទី១ សកម្មភាព
ចុះបញ្ជីអវត្តមាននៃអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋចូលរួម



រូបភាពទី២ សកម្មភាពសំណេះសំណាល និងណែនាំខ្លួន
មុនធ្វើការផ្សព្វផ្សាយផ្ទាំងរូបភាពនៃអត្ថប្រយោជន៍ព្រៃលិចទឹក



រូបភាពទី៣ សកម្មភាពសួរបញ្ជាក់ឡើងវិញ
ដល់អ្នកចូលរួមដើម្បីវាស់វែងការយល់ដឹងរបស់គាត់កំរិតណា
ក្រោយពីក្រុមអ្នកសម្របសម្រួលបានបង្ហាញនិងពន្យល់ដល់ពួកគាត់



រូបភាពទី៤ សកម្មភាពពន្យល់ និងបញ្ជាក់បន្ថែម
អំពីសារៈសំខាន់នៃព្រៃលិចទឹករបស់នាយខណ្ឌ
រដ្ឋបាលជលផលដល់ប្រជាពលរដ្ឋដែលបានចូលរួម